# សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ
# នៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទីពីរ
# «ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព»

យើងជាប្រមុខរដ្ឋ/រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានមកជួបជុំគ្នានៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំកំពូលសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ ក្រោមមូលបទ «**ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព**» និងរៀបចំផែនការពេលអនាគតនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងក្នុងទសវត្សរ៍ខាងមុខនេះ។

១. ទទួលស្គាល់ថា ប្រទេសទាំងប្រាំមួយ មានទីតាំងភូមិសាស្ត្រស្ថិតក្នុងអនុតំបន់រួមគ្នា តភ្ជាប់គ្នាដោយទន្លេមេគង្គ-ឡានឆាង។ លើសពីនេះ ចំពោះទិដ្ឋភាពនយោបាយ មានសេចក្តីពេញចិត្តដែលបណ្តាប្រទេសមេគង្គ-ឡានឆាងទាំងប្រាំមួយក្នុងរយៈពេលពីរឆ្នាំមកនេះ បានប្រែក្លាយនូវគំនិតមួយដែលចាប់ផ្តើមនៅទីក្រុងណៃពិដោ ក្នុងអំឡុងកិច្ចប្រជុំកំពូលចិន-អាស៊ានលើកទី១៧ និងបានផ្លាស់ប្តូរពីដំណាក់កាលកកើតឲ្យទៅជាកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឬ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គយ៉ាងពេញលេញ និងរស់រវើក។

២. គូសបញ្ជាក់ពីទស្សនវិស័យ និងសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៃបណ្តាប្រទេសអនុតំបន់ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋដោយកាត់បន្ថយគម្លាតអភិវឌ្ឍន៍ក្នុងចំណោមបណ្តាប្រទេសនានា ក្នុងការគាំទ្រដល់ការកសាងសហគមន៍អាស៊ាន ក៏ដូចជាការជំរុញដល់កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដើម្បីលើកកម្ពស់បន្ថែមទៀតនូវការអនុវត្តរបៀបវារៈ២០៣០របស់អង្គការសហប្រជាជាតិ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

៣. រំលឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើង ដូចមានចែងនៅក្នុង "សេចក្តីថ្លែងការណ៍ទីក្រុងសានយ៉ានៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១" ដើម្បីកសាងសហគមន៍ដែលមានអនាគតរួមគ្នា ប្រកបដោយសន្តិភាព ស្ថិរភាព និងវិបុលភាព សម្រាប់ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់អនុតំបន់ និងការប្តេជ្ញាចិត្តដើម្បីពង្រឹងការចិត្ត និងការយោគយល់គ្នាទៅវិញទៅមក ក្នុងការដោះស្រាយបញ្ហាប្រឈមដែលអនុតំបន់បានជួបប្រទះផ្នែកសេដ្ឋកិច្ច សង្គម

បរិស្ថាន និងការគំរាមកំហែងផ្នែកសន្តិសុខមិនប្រពៃណី ដើម្បីឈានទៅសម្រេចនូវសក្តានុពលអភិវឌ្ឍន៍ដ៏ធំធេងរបស់អនុតំបន់។

៤. ស្វាគមន៍ចំពោះជោគជ័យនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី២ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅខេត្តសៀមរាប ប្រទេសកម្ពុជា និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី៣ កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ នៅក្រុងតាលី ខេត្តយូណាន ប្រទេសចិន ដែលសម្រេចបាននូវឯកសារគោលនយោបាយយុទ្ធសាស្ត្រមួយចំនួន ដូចជាគោលការណ៍ទូទៅសម្រាប់ការបង្កើតក្រុមការងាររួមលើវិស័យអាទិភាពគន្លឹះនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង សេចក្តីប្រកាសព័ត៌មានរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាងលើកទីពីរ និងលើកទីបី និងផែនការសកម្មភាពប្រាំឆ្នាំស្តីពីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២២)។

៥.ស្វាគមន៍ចំពោះសមិទ្ធផលជាក់ស្តែងជាលក្ខណៈស្ថាប័ននៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដូចជាការបង្កើត និងការបើកឲ្យប្រើប្រាស់នូវមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹក មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ-ឡានឆាង មជ្ឈមណ្ឌលសកលនៃការសិក្សាទន្លេមេគង្គ និងដំណើរការនៃមូលនិធិពិសេសរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៦. ទទួលស្គាល់ការបង្កើតយ៉ាងពេញលេញ នូវលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលជាតិនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅក្នុងប្រទេសទាំងប្រាំមួយ ដែលជាឆ្អឹងខ្នងនៃយន្តការអនុវត្តកិច្ចសហប្រតិបត្តិការ ក្នុងការសម្របសម្រួល និងសម្រេចនូវលទ្ធផលជាក់ស្តែងឲ្យមានប្រសិទ្ធភាពលើគ្រប់វិស័យកិច្ចសហប្រតិបត្តិការទាំងឡាយ។

៧. កោតសរសើរខ្ពស់ចំពោះការបង្កើតមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដោយប្រទេសចិន និងការចាប់ផ្តើមដំណើរការទទួលទម្រង់បែបបទ ដើម្បីគាំទ្រគម្រោងនានា សំដៅជំរុញកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរជាមិត្តភាព ដើម្បីផលប្រយោជន៍របស់ប្រជាជននៃប្រទេសទាំងប្រាំមួយ។

៨. កត់សម្គាល់ដោយសេចក្តីសោមនស្ស ដែលភាគច្រើននៃគម្រោងឆាប់ទទួលបានផលភ្លាមៗចំនួន៤៥ ដែលបានកំណត់ក្នុងកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី១ ហើយគំនិតផ្តួចផ្តើមចំនួន១៣ ដែលដាក់ចេញដោយប្រទេសចិននៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី២ ត្រូវបានបញ្ចប់ការអនុវត្ត ឬសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលបានបង្កើតគ្រឹះដ៏រឹងមាំសម្រាប់គម្រោងបន្តបន្ទាប់នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៩. ខិតខំប្រឹងប្រែងបន្តអនុវត្តស្មារតីកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលជាការបើកចំហរ បរិយាប័ន្ន និងការបំពេញបន្ថែមជាមួយនឹងវិស័យអាទិភាពនៃការកសាងសហគមន៍អាស៊ាន កិច្ចសហប្រតិបត្តិការអាស៊ាន-ចិន និងសហថាមភាពជាមួយក្របខណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់ដែលមានស្រាប់។

១០. ទទួលស្គាល់នូវកម្លាំងផ្លាស់ប្តូរនៃសាកលភាវូបនីយកម្ម និន្នាការនៃការអភិវឌ្ឍ និងការប្តេជ្ញាចិត្តដើម្បីបង្កើនកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ ដោយការស្វែងរកការរួមបញ្ចូលគ្នានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដូចជាផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ គំនិតផ្តួចផ្តើមដើម្បីសមាហរណកម្មអាស៊ាន ផែនការការងារជំហានទី៣នៃរបៀបវារៈអង្គការសហប្រជាជាតិ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ ដោយបន្សុីគ្នាដោយយកចិត្តទុកដាក់ជាមួយនឹងយុទ្ធសាស្ត្រជាតិ ទស្សនវិស័យអភិវឌ្ឍន៍ និងផែនការទូទៅរបស់បណ្តាប្រទេសមេគង្គ-ឡានឆាងនីមួយៗ។

១១. ឈរលើគោលការណ៍កុងសង់ស៊ីស សមភាព ការប្រឹក្សា និងការសម្របសម្រួលគ្នាទៅវិញទៅមក ការស្ម័គ្រចិត្ត ការរួមចំណែកគ្នា និងការចែករំលែកផលប្រយោជន៍ និងការគោរពចំពោះធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ។

១២. ដោយមានការជំរុញពីការវិវត្តយ៉ាងឆាប់រហ័សរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ពីដំណាក់កាលចិញ្ចឹមបីបាច់ថែរក្សា ទៅដំណាក់កាលរីកលូតលាស់ដូចបច្ចុប្បន្ន ហើយមានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតក្នុងវិស័យអាទិភាពទាំងប្រាំ និងពង្រីកកិច្ចសហប្រតិបត្តិការទៅលើវិស័យថ្មីៗផ្សេងទៀត ដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ចំពោះមុខនៃបណ្តាប្រទេសមេគង្គ-ឡានឆាង ព្រមទាំងបង្កើនប្រសិទ្ធភាពគំរូនៃកិច្ចសហប្រតិបត្តិការសំដៅសហការដោយសន្សឹមៗឈានទៅរកគម្រោងអនុតំបន់ខ្នាតធំ ដូចជាការរួមគ្នាកសាងខ្សែក្រវាត់អភិវឌ្ឍន៍សេដ្ឋកិច្ចនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

អំណឹះតទៅនេះយើងសូមប្រកាសដូចតទៅ៖

## I. កិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខ

កិច្ចសហប្រតិបត្តិការនយោបាយ និងសន្តិសុខ មានសារៈសំខាន់ណាស់សម្រាប់គំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។ យន្តការកិច្ចសហប្រតិបត្តការពហុកម្រិត គឺជាបណ្តាញដែលមានប្រសិទ្ធភាពសម្រាប់ការសម្របសម្រួលទំនាក់ទំនង ការពង្រឹងកិច្ចសម្របសម្រួលគោលនយោបាយ និង

ការលើកកម្ពស់នូវទំនុកចិត្តគ្នាទៅវិញទៅមកលើផ្នែកនយោបាយ។ ដូចនេះ យើងប្ដេជ្ញាគាំទ្រនូវវិធានការនានាដូចខាងក្រោម:

១.១. ជំរុញការផ្លាស់ប្តូរកម្រិតខ្ពស់ និងកិច្ចសន្ទនាក្នុងចំណោមមន្ត្រីគណបក្សនយោបាយ សភា និងរដ្ឋាភិបាល ស្របតាមស្មារតីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

១.២. ពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីរក្សាសន្តិភាព និងស្ថិរភាព ក្នុងអនុតំបន់ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃទៀត។

១.៣. ពង្រឹងកិច្ចសន្ទនាលើការអនុវត្តច្បាប់ និងកិច្ចសហប្របត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាសន្តិសុខមិនប្រពៃណី ដើម្បីផលប្រយោជន៍រួម។

១.៤. ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យទប់ស្កាត់ និងកាត់បន្ថយគ្រោះមហន្តរាយ ជំនួយមនុស្សធម៌ ដោយលើកឡើងអំពីផលប៉ះពាល់នៃបំរែបំរួលអាកាសធាតុ ការធានានូវសន្តិសុខស្បៀង ទឹក និងថាមពល រួមបញ្ចូលទាំងការផ្លាស់ប្តូរទិន្នន័យព័ត៌មាន។

## II. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព

អនុតំបន់មេគង្គ-ឡានឆាង ទទួលស្គាល់ថាជាទីតាំងយុទ្ធសាស្ត្រ ដែលមានភាពខ្លាំងផ្សេងៗគ្នា ដោយកំណើនសក្តានុពលសេដ្ឋកិច្ច និងកម្លាំងម៉ាស៊ីនដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចសាកល។ ដើម្បីបន្តតួនាទីជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ច កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងអំពាវនាវឱ្យបង្កើននូវការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្នែករឹងនិងទន់ និងការសម្របសម្រួលផ្សេងៗ ពង្រឹងការកែលម្អរចនាសម្ព័ន្ធឧស្សាហកម្ម និងនគរូបនីយកម្ម ពាណិជ្ជកម្មគ្មានដែនកំណត់ ការធ្វើសមាហរណកម្មហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងរដ្ឋាភិបាល និងវិស័យឯកជន។ ដូចនេះ យើងប្តេជ្ញាគាំទ្រវិធានការដូចខាងក្រោមៈ

២.១. លើកកម្ពស់ការតភ្ជាប់ក្នុងបណ្តាប្រទេសមេគង្គ-ឡានឆាង និងការតភ្ជាប់អន្តរតំបន់ ដោយរៀបចំផែនការកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើវិស័យតភ្ជាប់ ជំរុញបន្ថែមនូវការអភិវឌ្ឍពាណិជ្ជកម្ម ការវិនិយោគ ឧស្សាហកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការច្នៃប្រឌិតហេដ្ឋារចនាសម្ព័ន្ធ ការសម្របសម្រួលការដឹកជញ្ជូន ទេសចរណ៍ និងការតភ្ជាប់ប្រជាជន-ប្រជាជន ក្នុងការបំពេញបន្ថែមឱ្យផែនការមេនៃការតភ្ជាប់អាស៊ាន។

២.២.ស្វែងរកលទ្ធភាពដើម្បីបង្កើតច្រករបៀងសេដ្ឋកិច្ចមួយនៅក្នុងតំបន់ ដើម្បីលើកកម្ពស់ការតភ្ជាប់គ្រប់ជ្រុងជ្រោយនៅក្នុងចំណោមបណ្តាប្រទេសមេគង្គ-ឡានឆាង ដើម្បីពន្លឿនឧស្សាហូបនីយកម្ម ក៏ដូចជាជំរុញកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតក្នុងអនុតំបន់ ដោយយកចិត្តទុកដាក់លើតម្រូវការស្របតាមយុទ្ធសាស្ត្រសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ និងតាមគុណវុឌ្ឍិរបស់បណ្តាប្រទេសមេគង្គ-ឡានឆាងនីមួយៗ។

២.៣. លើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន លើវិស័យនានាដូចជា ពាណិជ្ជកម្ម វិនិយោគ ពាណិជ្ជកម្មអេឡិចត្រូចនិច កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស សួនឧស្សាហកម្ម តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន និងការសម្របសម្រួលពាណិជ្ជកម្ម។ ប្រទេសចិនអញ្ជើញរដ្ឋាភិបាល និងសហគ្រាសពីបណ្តាប្រទេសមេគង្គឱ្យចូលរួមពិព័រណ៍អន្តរជាតិនាំចូលរបស់ចិន ហើយនឹងផ្តល់ការគាំទ្រចាំបាច់។ បណ្តាប្រទេសមេគង្គអរគុណចំពោះការអញ្ជើញរបស់ចិន។

២.៤.បង្កើត "ផែនការសកម្មភាពស្តីពីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតក្នុងចំណោមបណ្តាប្រទេសមេគង្គ-ឡានឆាង" ស្របតាម "សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតក្នុងចំណោមបណ្តាប្រទេស មេគង្គ-ឡានឆាង" ដោយផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការលើកកម្ពស់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព ការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន ការបង្កើតការងារ ការកសាងសមត្ថភាព ការកាត់បន្ថយភាពក្រីក្រ និងការផ្ទេរជំនាញ និងចំណេះធ្វើ ការពង្រឹងការផ្លាស់ប្តូរឧស្សាហកម្មក្នុងចំណោមសមាជិកប្រទេសមេគង្គ-ឡានឆាង និងទីតាំងរបស់ខ្លួន ក្នុងសង្វាក់ផលិតកម្មក្នុងតំបន់ និងសកល ព្រមទាំងបង្កើនប្រសិទ្ធភាពការចែកចាយផលិតភាពក្នុងតំបន់ ដោយគិតគូរពីគោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមក និងលទ្ធផលឈ្នះ-ឈ្នះ។

២.៥.ពង្រឹងកិច្ចសហប្រតិបត្តិការ ស្តីពីការគ្រប់គ្រងប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈកិច្ចសន្ទនាគោលនយោបាយ ការចែករំលែកទិន្នន័យ និងព័ត៌មាន កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការផ្លាស់ប្តូរ ការចូលរួមការស្រាវជ្រាវរួម និងវិភាគពាក់ព័ន្ធនឹងធនធានទឹកមេគង្គ-ឡានឆាង ការលើកកម្ពស់ការកសាងសមត្ថភាពក្នុងការគ្រប់គ្រងទឹក ការពង្រឹងការគ្រប់គ្រងបន្ទាន់នូវគ្រោះរាំងស្ងួត និងទឹកជំនន់ក្នុងទន្លេមេគង្គ និងការ

ប្រើប្រាស់ពេញលេញនូវវេទិកាធនធានទឹកនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង ដើម្បីជាវេទិកាគាំទ្រ។

២.៦.ធ្វើឱ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនវ័យក្មេង នៅក្នុងការវិនិយោគដែលមានសក្តានុពល និងកាលានុវត្តភាពអាជីវកម្ម នៅប្រទេសមេគង្គ-ឡានឆាងនានា ព្រមទាំងជំរុញឱ្យមានទំនាក់ទំនងល្អប្រសើរ និងការផ្សាភ្ជាប់កាន់តែរឹងមាំរវាងធុរជននៃប្រទេសមេគង្គ-ឡានឆាង តាមមធ្យោបាយនៃការបង្កើតក្រុមប្រឹក្សាធុរកិច្ចមេគង្គ-ឡានឆាង និងសកម្មភាពនៃការរៀបចំការផ្សព្វផ្សាយពាណិជ្ជកម្មឱ្យបានញឹកញាប់ ដូចជាការរៀបចំពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ការតាំងពិពណ៌ និងកិច្ចប្រជុំផ្គូរផ្គងពាណិជ្ជកម្ម។

២.៧.ជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើផ្នែកហិរញ្ញវត្ថុ និងបន្តសិក្សានិងការផ្លាស់ប្តូរបទពិសោធន៍ស្តីពីការចរាចររូបិយប័ណ្ណក្នុងស្រុកក្នុងពាណិជ្ជកម្ម និងវិនិយោគអនុតំបន់ដើម្បីលើកកម្ពស់កំណើនដ៏រឹងមាំនៃសេដ្ឋកិច្ចរបស់អនុតំបន់ ព្រមទាំងស្វែងរកវេទិកាច្នៃប្រឌិតថ្មី ដើម្បីសហការក្នុងការធ្វើហិរញ្ញប្បទានវិនិយោគ ដើម្បីគាំទ្រដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពនៅក្នុងប្រទេសមេគង្គ-ឡានឆាង ស្របពេលដែលបង្កើនភាពឈ្នះជាមួយយន្តការហិរញ្ញវត្ថុតំបន់ដែលមានស្រាប់ ផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមធនាគារពិភពលោក និងប្រភពដទៃទៀតដូចជាមូលនិធិផ្លូវសូត្រ។

## III. ការផ្លាស់ប្តូរទំនាក់ទំនងសង្គម វប្បធម៌ និងប្រជាជន-ប្រជាជន

តំបន់មេគង្គ-ឡានឆាង មានមោទនភាពចំពោះភាពសម្បូរបែបនៃប្រពៃណី វប្បធម៌ និងគុណតម្លៃក្នុងស្រុក បានបង្ហាញពីកំលាំង និងសក្តានុពលបំពេញបន្ថែមដែលអាចយកទៅប្រើប្រាស់សម្រាប់ផលប្រយោជន៍រួមនៃបណ្តាប្រទេសមេគង្គ-ឡានឆាង។ ដូចនេះ យើងប្តេជ្ញាគាំទ្រវិធានការដូចខាងក្រោម៖

៣.១.លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការចូលរួមបន្ថែមទៀត លើគំនិតផ្តួចផ្តើមនៃការផ្សារភ្ជាប់ប្រជាជន-ប្រជាជន រួមមានការអភិវឌ្ឍធនធានមនុស្ស ការផ្លាស់ប្តូរការអប់រំ និងការសិក្សារយៈពេលវែង។

៣.២.គាំទ្រវិស័យសិក្សាធិការ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីរួមចំណែក និងដើរតួនាទីជាស្ពានតភ្ជាប់នូវគម្លាតក្នុងការអភិវឌ្ឍធនធានមនុស្ស និងការកសាងកម្លាំងពលកម្មដែលមានភាព

ប្រកួតប្រជែងនាពេលអនាគតក្នុងតំបន់មេគង្គ-ឡានឆាង ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ជាពិសេសក្នុងសមត្ថភាពសំខាន់ៗដូចជា ជំនាញភាសា ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងឌីជីថល និងជំនាញផ្នែកទន់ដទៃទៀត។

៣.៣.បង្កើនការផ្លាស់ប្តូរវប្បធម៌ ក្នុងចំណោមប្រទេសទាំងប្រាំមួយ តាមរយៈការគាំទ្រការផ្លាស់ប្តូរពាក់ព័ន្ធនឹងស្ថាប័នអង្គការវប្បធម៌ វិចិត្រករ និងទេសចរវប្បធម៌ ព្រមទាំងស្វែងរកលទ្ធភាពនៃការបង្កើតវេទិកាផ្លាស់ប្តូរវប្បធម៌ឡានឆាង-មេគង្គមួយ។

៣.៤. ពង្រឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ តាមរយៈការកសាងសម្ព័ន្ធកិច្ចសហប្រតិបត្តិការទីក្រុងទេសចរណ៍មេគង្គ-ឡានឆាងមួយ។

៣.៤.ស្វែងរកនូវគំរូនៃការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការបញ្ញាវ័ន្ត ដែលរួមបញ្ចូលទាំងរដ្ឋាភិបាល ធុរកិច្ច សិក្សាធិការ និងអ្នកសិក្សាស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ ស្ត្រី និងយុវជន ដើម្បីផ្តល់នូវគំនិតច្នៃប្រឌិតថ្មី សំដៅគាំទ្រដល់ការអភិវឌ្ឍរយៈពេលវែងរបស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

## IV. ការគាំទ្រដល់កិច្ចសហប្រតិបត្តិការ

៤.១. បន្តស្វែងរកមធ្យោបាយនានា ដើម្បីបង្កើនប្រសិទ្ធភាពក្របខណ្ឌការងារពហុស្រទាប់ ដែលមានស្រាប់ រួមមានកិច្ចប្រជុំកំពូល កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំឧត្តមមន្ត្រី និងកិច្ចប្រជុំក្រុមការងារការទូត និងក្រុមការងាររួមតាមវិស័យអាទិភាពគន្លឹះ ដើម្បីតម្រែតម្រង់ និងធ្វើឱ្យប្រសើរឡើងដល់ការធ្វើផែនការគោលនយោបាយ និងការសម្របសម្រួលកិច្ចសហប្រតិបត្តិការ ព្រមទាំងកំណត់ផែនការយុទ្ធសាស្ត្ររយៈពេលវែងនៃការអភិវឌ្ឍកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៤.២. ពង្រឹងការប្រាស្រ័យទាក់ទង និងការសម្របសម្រួល ក្នុងចំណោមលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៃប្រទេសជាសមាជិកទាំងប្រាំមួយ ព្រមទាំងការពង្រឹងសមត្ថភាពបុគ្គលិក ដើម្បីធានានូវការអនុវត្តនៃគម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងប្រកបដោយប្រសិទ្ធភាព ជាមួយនឹងទស្សនៈនៃការស្វែងរកលទ្ធភាពបង្កើតលេខាធិការដ្ឋានអន្តរជាតិនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

៤.៣.អនុម័តផែនការសកម្មភាពប្រាំឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០១៨-២០២២) ដែលជាឯកសារតម្រង់ទិស និងត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្ពោះទៅរកយុគសម័យថ្មីមួយ និងគាំទ្រដល់ការបង្កើតផែនការសកម្មភាពប្រាំឆ្នាំក្នុងវិស័យអាទិភាពនីមួយៗ ដោយក្រុមការងាររួម ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការពាក់ព័ន្ធ។

៤.៤. ស្វាគមន៍ការបញ្ចប់សេចក្តីប្រកាសរួមថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសមេគង្គ-ឡានឆាង ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងកាត់ព្រំដែន។

៤.៥. ប្រើប្រាស់ឱ្យបានពេញលេញនូវមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងការស្វែងរកប្រភពធនធានហិរញ្ញវត្ថុផ្សេងៗទៀត ពីរដ្ឋាភិបាលនានា ផ្នែកធុរកិច្ច ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដើម្បីគាំទ្រគម្រោង និងគំនិតផ្តួចផ្តើមអាទិភាព ដែលស្របតាមចក្ខុវិស័យរបស់ថ្នាក់ដឹកនាំ និងទិសដៅ របស់រដ្ឋមន្ត្រីការបរទេស។

៤.៦. កសាងនិមិត្តសញ្ញានៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង តាមរយៈកុងសង់ស៊ីស ដែលបង្ហាញពីអត្តសញ្ញាណតែមួយ សម្រាប់ភាពងាយស្រួលក្នុងសកម្មភាពផ្សព្វផ្សាយ និងសកម្មភាពបង្កើនការយល់ដឹងជាសាធារណៈ និងរំលឹកខួបសប្តាហ៍នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងប្រចាំឆ្នាំនៅថ្ងៃទី២៣ ខែមីនា ដែលជាថ្ងៃនៃកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១ នៅឆ្នាំ២០១៦ នៅប្រទេសចិន។

* * * * *